# សុន្ទរកថា
# ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
# រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
# ថ្លែងក្នុង
# ពិធីបើកសន្និសីទអន្តរជាតិ ស្តីពី
# «ប្រវត្តិសាស្ត្រប្រទេសកម្ពុជា : កម្ពុជាក្នុងសម័យអាណានិគមបារាំង»

រាជបណ្ឌិត្យសភាកម្ពុជា, ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤

- *សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!*
- *ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តមរដ្ឋមន្ត្រី សមាជិក នៃរាជរដ្ឋាភិបាល!*
- *ឯកឧត្តមបណ្ឌិតសភាចារ្យ សុខ ទូច ប្រធានរាជបណ្ឌិត្យសភាកម្ពុជា!*
- *ឯកឧត្តម អគ្គរដ្ឋទូតនៃបណ្តាប្រទេសជាមិត្ត!*
- *ឯកឧត្តមបណ្ឌិតសភាចារ្យ លោកជំទាវបណ្ឌិតសភាចារ្យ ឯកឧត្តម លោកជំទាវ លោកសាស្ត្រាចារ្យបណ្ឌិត អស់លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ក្មួយៗយុវជន យុវនិស្សិត ជាទីមេត្រី!*

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកចូលរួមជាអធិបតីក្នុងសន្និសីទអន្តរជាតិ ស្តីពី «**ប្រវត្តិសាស្ត្រប្រទេសកម្ពុជា : កម្ពុជាក្នុងសម័យអាណានិគមបារាំង**» នាពេលនេះ។ ខ្ញុំសូមសម្តែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះរាជបណ្ឌិត្យសភាកម្ពុជា ដែលបានផ្តួចផ្តើមគំនិតរៀបចំសន្និសីទអន្តរជាតិដ៏មានសារៈសំខាន់នេះឡើង។ សន្និសីទអន្តរជាតិនេះពិតជាបានផ្តល់ឱកាសឱ្យយើងប្រមូលផ្តុំបាននូវទស្សនាទានដ៏ល្អៗ ក៏ដូចជាទស្សនៈផ្សេងគ្នា ក្នុងគោលបំណងចំនួន ៨ ចំណុច ដូចការលើកឡើងរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** មុននេះ។ ទន្ទឹមនេះ សន្និសីទអន្តរជាតិនេះ ក៏បានរំលេចឱ្យឃើញនូវវឌ្ឍនភាពថ្មីមួយបន្ថែមទៀត ក៏ដូចជាការឈានឡើងនៃសមត្ថភាពរបស់រាជបណ្ឌិត្យសភាកម្ពុជាផងដែរ។

ក្នុងនាមទីស្តីការគណៈរដ្ឋមន្ត្រី និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមយកឱកាសនេះថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវាគ្មិនជាតិ និងអន្តរជាតិ ព្រមទាំងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ដែលអញ្ជើញចូលរួមក្នុងសន្និសីទនេះ។ វត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់នៅក្នុងសន្និសីទនេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការចែករំលែកចំណេះដឹង, លទ្ធផលនៃការស្រាវជ្រាវផ្ទាល់ខ្លួន ព្រមទាំងផ្តល់នូវទស្សនាទាន និងធាតុចូលនានាដល់ក្រុមការងារសរសេរប្រវត្តិសាស្ត្ររបស់រាជបណ្ឌិត្យសភាកម្ពុជា សំដៅស្វែងរកការពិត និងសរសេរពីការពិតនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកម្ពុជា ដែលមានលក្ខណៈវិទ្យាសាស្ត្រ,

ភាពគ្រប់ជ្រុងជ្រោយ និងអាចទទួលយកបានទូលំទូលាយ ទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ នៅក្នុងការវិវត្តនៃទំព័រប្រវត្តិសាស្ត្រកម្ពុជា ចាប់ពីចំណុចចាប់ផ្តើមនៃការគ្រប់គ្រងរបស់បារាំងនៅឆ្នាំ១៨៦៣ រហូតដល់ការទទួលបាននូវឯករាជ្យនាឆ្នាំ១៩៥៣ ក្រោមព្រះរាជបូជនីយកិច្ចរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ។

## *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

កម្ពុជាជាប្រជាជាតិមួយ ដែលមានប្រវត្តិសាស្ត្រយូរលង់, ធ្លាប់មានទឹកដីធំទូលំទូលាយ, អារ្យធម៌ឧត្តុង្គឧត្តម, ថ្កុំថ្កើងរុងរឿង និងល្បីរន្ទឺ។ ចាប់ពីសតវត្សទី១ នៃគ្រិស្តសករាជ ប្រទេសកម្ពុជាបានឆ្លងកាត់នូវរបត់ប្រវត្តិសាស្ត្រជាច្រើន ហើយប្រវត្តិសាស្ត្រសម័យហ្វូណនឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជា គឺជាអាណាចក្រដំបូងគេបង្អស់ក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានសេដ្ឋកិច្ចរីកចម្រើនដោយពឹងផ្អែកលើកសិកម្ម និងជំនួញផ្លូវសមុទ្រតាមរយៈប្រព័ន្ធព្រែកជីកខ្វាត់ខ្វែងប្រទាក់គ្នា ភ្ជាប់ពីអាណាចក្រទៅកាន់កំពង់ផែសមុទ្រ និងទៅតំបន់ផ្សេងៗទៀត រហូតក្លាយជាអាណាចក្រដ៏ល្បីល្បាញក្នុងប្រវត្តិសាស្ត្រមនុស្សលោក គឺ **«អាណាចក្រអង្គរ»** ដែលរីកចម្រើនរុងរឿងក្នុងរយៈពេលជាង៥០០ឆ្នាំ ក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។

ប៉ុន្តែ ជាអកុសល ចាប់ពីសតវត្សទី១៤ មក ប្រទេសកម្ពុជាបានពើបប្រទះនឹងសង្គ្រាមឈ្លានពានផង និងជម្លោះផ្ទៃក្នុងផង គួបផ្សំនឹងបច្ច័យមិនល្អមួយចំនួនទៀត ដូចជាគ្រោះធម្មជាតិជាដើម ដែលប្រការទាំងអស់នេះបានធ្វើឱ្យប្រទេសជាតិធ្លាក់ចុះដុនដាប ហើយទឹកដីត្រូវរួមតូចបន្តិចម្តងៗ និងធ្លាក់ខ្លួនទៅក្នុងការគ្រប់គ្រងរបស់បារាំងអស់រយៈពេលជិត ១សតវត្ស។ រឹតតែជាអកុសលជាងនេះទៅទៀត នៅក្នុងប្រវត្តិសាស្ត្រទំនើបនៃកម្ពុជា ទឹកដីសុវណ្ណភូមិនេះបានធ្លាក់ក្នុងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ និងរបបវាលពិឃាដ អូសបន្លាយជិត៣ទសវត្សដែលបានបង្កវិនាសកម្មបំផ្លិចបំផ្លាញគ្រប់វិស័យ, ទាំងធនធានមនុស្ស ទាំងហេដ្ឋារចនាសម្ព័ន្ធរឹងនិងទន់ដោយក្នុងនោះឯកសារប្រវត្តិសាស្ត្រជាច្រើន ក៏ត្រូវបានបំផ្លាញផងដែរ។

ឆ្លងកាត់ភាពថមថយ, ការបែកបាក់, សង្គ្រាម និងការឈឺចាប់អស់រយៈពេលជាង ៥០០ឆ្នាំ កម្ពុជាទើបទទួលបានសន្តិភាពពេញលេញ និងឯកភាពជាតិនិងទឹកដីនាខែធ្នូ ឆ្នាំ១៩៩៨ ក្រោមនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលជាបិតាស្ថាបនិក និងប្រតិបត្តិករផ្ទាល់ក្នុងបេសកកម្មស្វែងរកសន្តិភាព, ការផ្សះផ្សាជាតិ និងឯកភាពទឹកដីជូនមាតុភូមិកម្ពុជា។ ពិតណាស់ **«សង្គ្រាមងាយបង្កើត តែលំបាកបញ្ចប់»**, **«សន្តិភាពពិបាករក តែងាយបាត់បង់»**។ ដូច្នេះ ការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រនឹងធ្វើឱ្យយើងចងចាំមេរៀនជូរចត់នៃសង្គ្រាម និងផ្តល់តម្លៃដល់គុណតម្លៃសន្តិភាព ព្រមទាំងចូលរួមថែរក្សាសន្តិភាព។ ម៉្យាងទៀតការសិក្សា រៀនសូត្រអំពីប្រវត្តិសាស្ត្ររបស់ខ្លួននឹងជួយបង្រៀនយើង, ដាស់តឿនយើង, តម្រង់ទិស និងកែតម្រូវយើងឱ្យចេះរស់, ឱ្យចេះកសាង, ឱ្យចេះលូតលាស់, ឱ្យចេះរឹងមាំ, ឱ្យចេះការពារ, ឱ្យចេះថែរក្សា និងឱ្យចេះស្រឡាញ់ជាតិ ក្នុងនាមជាប្រជាជាតិមួយ ដែលមានប្រវត្តិសាស្ត្រយូរលង់ និងមានវប្បធម៌និងអារ្យធម៌រុងរឿងកន្លងមក។

ដូចខ្ញុំបានបញ្ជាក់ពីខាងលើ ឯកសារប្រវត្តិសាស្ត្រជាច្រើនត្រូវបានបំផ្លាញ ឬបាត់បង់ ដោយសារសង្គ្រាម និងជម្លោះផ្ទៃក្នុងដ៏រ៉ាំរ៉ៃ។ ទន្ទឹមនេះ អស់រយៈពេលជាច្រើនសតវត្សមកហើយ ដែលការសិក្សា ការស្រាវជ្រាវ

និងការសរសេរប្រវត្តិសាស្ត្រកម្ពុជា នៅមានកម្រិតមែនទែន ដែលធ្វើឱ្យខ្មែរសឹងតែបាត់នូវព្រលឹងជាតិ និងអាចធ្វើឱ្យមានភាពភាន់ច្រឡំនៃប្រវត្តិសាស្ត្រ។ រហូតមកដល់ពេលនេះ ប្រវត្តិសាស្ត្រខ្មែរមួយចំនួននៅស្ថិតនៅលើផ្ទាំងសិលា ឬអាចនៅលើស្លឹករឹតនៅឡើយ ហើយក្រៅពីនេះ បើមាន គឺភាគច្រើនសរសេរជាភាសាបរទេសដោយជនបរទេស ដែលជាហេតុធ្វើឱ្យខ្វះការឯកភាពគ្នា និងសង្គតិភាពនៃខ្លឹមសារ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដោយអ្នកនិពន្ធ និងអ្នកស្រាវជ្រាវមួយចំនួនហាក់នៅមានទំនោរ និង ទស្សនៈផ្សេងគ្នាលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកម្ពុជា។ ជាការពិតណាស់ ជាតិសាសន៍ណាដែលមិនសិក្សានិងចងក្រងប្រវត្តិសាស្ត្ររបស់ខ្លួន ជាតិសាសន៍នោះអាចមានការវង្វេងប្រវត្តិសាស្ត្រ ហើយក៏បាត់បង់មោទនភាពជាតិផងដែរ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយថាមពល និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជារាជរដ្ឋាភិបាលក្នុងនីតិកាលមុនៗ ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខ បានយកចិត្តទុកដាក់, លើកទឹកចិត្ត និងណែនាំឱ្យមានការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិសាស្ត្រជាតិឱ្យបានស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយ ដើម្បីទុកឱ្យកូនខ្មែរជំនាន់ក្រោយបានសិក្សាស្រាវជ្រាវ និងឈ្វេងយល់ទូលំទូលាយអំពីប្រវត្តិសាស្ត្រជាតិខ្លួនឯង។ ក្នុងន័យនេះ ខ្ញុំសូមធ្វើការវាយតម្លៃខ្ពស់ចំពោះរាជបណ្ឌិត្យសភាកម្ពុជា ដែលបានបង្កើតក្រុមការងារសរសេរប្រវត្តិសាស្ត្រកម្ពុជា ដោយមានសមាសភាពចម្រុះមកពីស្ថាប័នជំនាញដែលពាក់ព័ន្ធជាច្រើន សំដៅបង្កើតឯកសារប្រវត្តិសាស្ត្រមួយមាន ៥ សម័យកាលៈ គឺសម័យបុរេប្រវត្តិ, សម័យមុនអង្គរ, សម័យអង្គរ, សម័យក្រោយអង្គរ និងសម័យទំនើប ដែលប្រសូតឡើងពីស្នាដៃ និងអ្នកស្រាវជ្រាវរបស់កូនខ្មែរយ៉ាងពិតប្រាកដ។ ក៏ប៉ុន្តែការសិក្សាស្រាវជ្រាវ ជាដំណើរវិវត្តន៍មួយដែលមិនចេះចប់ ដែលចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីផលិតបាននូវឯកសារមួយ ដែលមានសង្គតិភាពជាលក្ខណៈប្រវត្តិសាស្ត្រ និងគ្រប់ជ្រុងជ្រោយ ដែលមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន គឺដូចអ្វីដែលយើងបានរៀបចំនៅពេលនេះ ដោយមានការចូលរួមពីអ្នកជំនាញនិងអ្នកសិក្សាស្រាវជ្រាវមកពីគ្រប់ទិសទី ដើម្បីផ្លាស់ប្តូរទស្សនៈ និងឆ្លុះបញ្ចាំងទៅលើរបកគំហើញ ដែលក្រុមការងាររាជបណ្ឌិត្យសភាកម្ពុជាបានរកឃើញថា តើវាពិតជាត្រឹមត្រូវ ឬទាមទារឱ្យមានការកែតម្រូវ និងការបំពេញបន្ថែមកម្រិតណាទៀត។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមធ្វើការគូសបញ្ជាក់ថា តាមពិតខ្ញុំបានស្នើឱ្យរាជបណ្ឌិត្យសភាកម្ពុជាឱ្យរៀបចំសន្និសីទអន្តរជាតិស្តីពីកម្ពុជាសម័យមុនអង្គរ។ ប៉ុន្តែ ខ្ញុំបានផ្តល់ការអនុញ្ញាតជាគោលការណ៍តាមសំណើរបស់រាជបណ្ឌិត្យសភាកម្ពុជា ក្នុងការរៀបចំសន្និសីទអន្តរជាតិសម័យអាណានិគមបារាំងនេះឡើង ដោយសារក្រុមការងារនៃរាជបណ្ឌិត្យសភាកម្ពុជាបានបញ្ចប់ការសរសេរ ១០០% រួចហើយ ដែលចាំបាច់ត្រូវប្រមូលធាតុចូល និងមតិយោបល់បន្ថែមពីអ្នកសិក្សាស្រាវជ្រាវ និងអ្នកចូលរួមទាំងអស់។ មួយវិញទៀត, ការសម្រេចរបស់ខ្ញុំ ក៏ឈរលើគោលការណ៍មិនជ្រៀតជ្រែកកិច្ចការបច្ចេកទេសនៃការងារស្រាវជ្រាវ និងឯករាជ្យភាពរបស់ស្ថាប័នស្រាវជ្រាវផងដែរ។ ប៉ុន្តែសម្រាប់ឆ្នាំ២០២៥ ខាងមុខ ខ្ញុំស្នើសុំឱ្យរាជបណ្ឌិត្យសភាកម្ពុជារៀបចំសន្និសីទអន្តរជាតិ ដោយចាប់ផ្តើមពីសម័យបុរេប្រវត្តិ ឬក៏អាចយកសម័យហ្វូណនក៏បាន។

ជាមួយគ្នានេះ ខ្ញុំក៏សូមលើកទឹកចិត្តដល់រាជបណ្ឌិត្យសភាកម្ពុជាឱ្យបន្តបេសកកម្មស្រាវជ្រាវរបស់ខ្លួនឱ្យបានហ្មត់ចត់ និងច្បាស់លាស់បន្ថែមទៀត។ ខ្ញុំយល់ថា ការស្រាវជ្រាវ និងការសរសេរអំពីការពិតក្នុងប្រវត្តិសាស្ត្រ គឺពិតជាប្រទីបបំភ្លឺផ្លូវ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូបឱ្យស្គាល់អត្តសញ្ញាណខ្លួនជានរណា? មកពីណា? ហើយត្រូវទៅណាទៀតនៅពេលអនាគត ដោយដកស្រង់មេរៀន និងបទពិសោធពីប្រវត្តិសាស្ត្ររបស់ខ្លួន។

ទន្ទឹមនេះ ការស្រាវជ្រាវនិងការសរសេរអំពីការពិតក្នុងប្រវត្តិសាស្ត្រ គឺពិតជាមិនមានគោលដៅផ្ទុះឆ្មៀល ឬបង្ក ទំនាស់ជាមួយអ្នកណា ឬប្រទេសណាមួយឡើយ។ ផ្ទុយទៅវិញ គឺជាវិធីបញ្ចប់ការខ្វែងគំនិត ឬការស្អប់ ឬការ បង្កជម្លោះ ឬការប្រឆាំងគ្នាទៅវិញទេ។ លើសពីនេះ វានឹងជួយបង្កើតលម្ហសម្រាប់កិច្ចសហប្រតិបត្តិការ និង ការកសាងចំណងទាក់ទងល្អ សម្រាប់ជាប្រយោជន៍ទៅវិញទៅមក សម្រាប់ប្រទេសនិងប្រជាជនពាក់ព័ន្ធ ផងដែរ។ ដូចខ្ញុំបានបញ្ជាក់ពីខាងលើអម្បាញ់មិញនេះ បើយើងនិយាយពីប្រវត្តិសាស្ត្រ គឺយើងនិយាយពីការ ពិត ដោយផ្អែកលើទិន្នន័យ, ភស្តុតាង និងទឡ្ហីករណ៍ជាក់លាក់ មិនមែននិយាយតាមអារម្មណ៍ ឬតាមការភ័យ ខ្លាច ភាគីណាមួយអាក់អន់ស្រពន់ចិត្ត ឬយកវេទិកានេះ មកដុតរោលដើម្បីចងកំហឹងរវាងជាតិសាសន៍និង ជាតិសាសន៍ណាមួយនោះឡើយ។

## ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ខ្ញុំយល់ថា ក្នុងរយៈពេលជាង ៩០ឆ្នាំ ឬជិត ១សតវត្ស ដែលកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ បារាំង អាចត្រូវបានចែកចេញជាពីរដំណាក់កាល គឺដំណាក់កាលទី១ ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៨៨៤ អាចចាត់ ទុកថាជាដំណាក់កាលអាណាព្យាបាលបារាំង និងដំណាក់កាលទី២ ពីឆ្នាំ១៨៨៤ដល់ឆ្នាំ១៩៥៣ អាចចាត់ ទុកថាជាដំណាក់កាលអាណានិគមបារាំង។ ទោះជាយ៉ាងណាក៏ដោយ បញ្ហានេះ គឺជាកម្មវត្ថុនៃការពិភាក្សានៅ ក្នុងសន្និសីទនេះ គឺថាតើក្នុងរយៈពេលជាង ៩០ឆ្នាំ ដែលកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង ត្រូវ កំណត់ហៅយ៉ាងដូចម្តេច? តើកម្ពុជាស្ថិតក្រោមអាណាព្យាបាលបារាំង ឬក៏ស្ថិតក្រោមអាណានិគមបារាំង? ហើយឈរលើទឡ្ហីករណ៍អ្វី? ខ្ញុំជឿជាក់ថា គណៈវាគ្មិនរបស់យើងនឹងមានអំណះអំណាងជាច្រើនលើបញ្ហា នេះ ដោយផ្អែកលើគោលការណ៍ និយមន័យ ព្រមទាំងភស្តុតាងជាក់ស្តែងនិងជាក់លាក់។ ដូចដែល ខ្ញុំបាន បញ្ជាក់ខាងលើរួចហើយ បើយើងនិយាយពីប្រវត្តិសាស្ត្រ គឺយើងនិយាយការពិត, នោះទើបប្រវត្តិសាស្ត្រជា លេខាកត់ត្រាគ្រប់ហេតុការណ៍ក្នុងសង្គមបានត្រឹមត្រូវ និងច្បាស់លាស់ ដោយមិនមានការបញ្ចេញបញ្ចូល លើសពីការពិត។

ទន្ទឹមនេះ ផ្អែកលើឯកសារដែលកំពុងស្រាវជ្រាវដោយរាជបណ្ឌិត្យសភាកម្ពុជា, ជាមតិផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំយល់ឃើញថា ក្នុងរយៈពេលជាង ៩០ឆ្នាំ ដែលបារាំងគ្រប់គ្រងកម្ពុជា គឺមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ ជាគុណសម្បត្តិធំបំផុតនៃគ្រប់គ្រងរបស់បារាំង គឺបានជួយការពារមាតុភូមិកម្ពុជាពីការឈ្លានពានពីសំណាក់ ប្រទេសជិតខាង បន្ទាប់ពីកម្ពុជាបានធ្លាក់ចូលទៅក្នុងសម័យកាលដ៏អាក្រក់បំផុតដែលអ្នកស្រាវជ្រាវខ្លះហៅថា **"សម័យខ្មៅងងឹត"** ក្នុងរវាងសវត្សទី១៧ និង១៩។ ពិតណាស់ ប្រសិនបើគ្មានវត្តមានបារាំងទេ ប្រហែលជា អាចលែងមានប្រទេសកម្ពុជានៅលើផែនទីពិភពលោកហើយ ឬមួយជនជាតិខ្មែរអាចក្លាយជាជនជាតិភាគតិច លើទឹកដីខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងក្របខ័ណ្ឌទឹកដីនេះ គឺមានទាំងទិដ្ឋភាពវិជ្ជមាន និង អវិជ្ជមានផងដែរ។ ជាមួយគ្នានេះ ការគ្រប់គ្រងរបស់បារាំងក៏បាននាំមកនូវការផ្លាស់ប្តូរលើគ្រប់ទិដ្ឋភាពនៃសង្គម កម្ពុជា ដូចជាវិស័យសេដ្ឋកិច្ច, ប្រព័ន្ធអភិបាលកិច្ច, ច្បាប់ និងការអប់រំជាដើម។ល។ ហើយបន្តមានឥទ្ធិពលរហូត មកដល់សព្វថ្ងៃ។ ប៉ុន្តែការគ្រប់គ្រងនេះក៏បានមកនាំនូវគុណវិបត្តិដល់កម្ពុជាផងដែរ ហើយថែមទាំងបាន បន្សល់ទុកនូវបញ្ហាដោះស្រាយមិនទាន់ចប់ខ្លះថែមទៀត ដូចជាបញ្ហាព្រំដែនជាដើម។ល។ ដែលមិនខុស គ្នាពីអាណានិគមដទៃនៅកន្លែងផ្សេងទៀតនោះទេ។ ក្នុងន័យនេះ ខ្ញុំសូមស្នើនិងលើកទឹកចិត្តដល់បញ្ញវន្ត, អ្នក

សិក្សាស្រាវជ្រាវ, សាស្ត្រាចារ្យ, និស្សិត និងអ្នកចូលរួមទាំងអស់ សូមចូលរួមសិក្សាស្រាវជ្រាវឱ្យសកម្ម និងស៊ីជម្រៅអំពីគុណសម្បត្តិ និងគុណវិបត្តិទាំងនេះ ក៏ដូចជាអំពីការតស៊ូរើបម្រាសរបស់កម្ពុជានាសម័យនោះ ក្នុងការរក្សានូវអត្តសញ្ញាណជាតិ, វប្បធម៌ប្រពៃណី, សាសនា និងអក្សរសាស្ត្រ ក៏ដូចជាការការពារទឹកដីរបស់ខ្លួនជាដើម ។ល។ យើងត្រូវតែរក្សាហេតុការណ៍ទាំងនេះ មិនត្រឹមតែសម្រាប់តម្លៃប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមគ្គុទ្ទេសក៍សម្រាប់យើងក្នុងដំណើររួបរួម កសាង និងការពារជាតិរបស់ខ្លួននៅថ្ងៃមុខថែមទៀត។

### *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ខ្ញុំសង្ឃឹមជឿជាក់ថា សន្និសីទអន្តរជាតិ ស្តីពី «**ប្រវត្តិសាស្ត្រប្រទេសកម្ពុជា : កម្ពុជាក្នុងសម័យអាណានិគមបារាំង**» នឹងក្លាយជាសក្ខីភាពមួយចំពោះការប្តេជ្ញាចិត្តដ៏ខ្ជាប់ខ្ជួនរបស់យើងចំពោះប្រវត្តិសាស្ត្រ ការរៀនសូត្រ និងការរីកចម្រើនជានិរន្តរ៍របស់ប្រទេសកម្ពុជា ព្រមទាំងជាកញ្ចក់មួយឆ្លុះបញ្ចាំងឱ្យឃើញនូវកាលានុវត្តភាព បញ្ហាប្រឈម និងទស្សនវិស័យសម្រាប់ជាគំនិតនិងជាគុចូលដ៏សំខាន់ដល់ក្រុមការងារសរសេរប្រវត្តិសាស្ត្រនៃរាជបណ្ឌិត្យសភាកម្ពុជា ក៏ដូចជាប្រជាជាតិយើងទាំងមូលផងដែរ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នករាល់គ្នាសម្រាប់ការយកចិត្តទុកដាក់ចំពោះការងារដ៏សំខាន់នេះ ហើយខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងសម្តែងនូវការកោតសរសើរដ៏កក់ក្តៅចំពោះរាជបណ្ឌិត្យសភាកម្ពុជា ដែលបានផ្តួចផ្តើមគំនិតនិងរៀបចំសន្និសីទអន្តរជាតិ ស្តីពី «**ប្រវត្តិសាស្ត្រប្រទេសកម្ពុជា : កម្ពុជាក្នុងសម័យអាណានិគមបារាំង**» នេះឡើង។ ទន្ទឹមនេះ តាមរយៈការយកចិត្តទុកដាក់របស់អ្នកទាំងអស់គ្នា ចំពោះការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ គឺពិតជាចូលរួមចំណែកយ៉ាងសំខាន់ក្នុងការការពារភាពសម្បូរបែបនៃអតីតកាលរបស់យើង សម្រាប់មនុស្សជំនាន់ក្រោយ។ ខ្ញុំសូមជូនពរឱ្យសន្និសីទនេះ ទទួលបានជោគជ័យ និងលទ្ធផលជាផ្លែផ្កាដ៏ល្អប្រសើរ តាមការរំពឹងទុក។

ជាទីបញ្ចប់ ខ្ញុំសូមប្រគេនពរនិងជូនពរ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ បណ្ឌិតសភាចារ្យ ឯកឧត្តម លោកជំទាវ បណ្ឌិត លោក លោកស្រីទាំងអស់ បានប្រកបដោយពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកសន្និសីទអន្តរជាតិស្តីពី «**ប្រវត្តិសាស្ត្រប្រទេសកម្ពុជា : កម្ពុជាក្នុងសម័យអាណានិគមបារាំង**» ចាប់ពីពេលនេះតទៅ!

**សូមអរព្រះគុណ និងសូមអរគុណ!**